គំរូនៃសេចក្តីប្រកាស

ការប្រើសេចក្តីប្រកាសនេះត្រូវបានអនុញ្ញាតដោយក្រមច្បាប់ RCW 7.70.065។

# អ្នកផ្តល់ការមើលថែទាំដោយភាពជាសាច់ញាតិ

## សេចក្តីប្រកាសនៃការទទួលខុសត្រូវសំរាប់ការមើលថែទាំសុខភាពអនីតិជន

(ដោយរួមមានសុខភាពវេជ្ជសាស្ត្រ, ធ្មេញ, និងផ្លូវសតិ)

ខ្ញុំសូមប្រកាសថា ៖

ព័ត៌មាននៃអនីតិជន ៖

1. ខ្ញុំយល់ព្រមមើលថែទាំសុខភាពសំរាប់ក្មេងរូបនេះ ៖ ____________________
(សរសេរឈ្មោះរបស់ក្មេង)

2. ខែថ្ងៃឆ្នាំកំណើតរបស់ក្មេងគឺ ៖ ____________

ពត៌មានអ្នកផ្តល់ការបំរើ ៖

3. ឈ្មោះរបស់ខ្ញុំគឺ ៖ ____________________
(សរសេរឈ្មោះរបស់អ្នក)

4. អាសយដ្ឋានផ្ទះរបស់ខ្ញុំគឺ ៖ ____________________
____________________

5. ខ្ញុំមានអាយុ 18 ឆ្នាំឬចាស់ជាង ហើយខ្ញុំត្រូវជាសាច់ញាតិដែលទទួលខុសត្រូវលើការថែទាំសុខភាពរបស់អនីតិជនរូបនេះ, ដោយរួមមានទាំងការថែទាំសុខភាពវេជ្ជសាស្ត្រ, ធ្មេញ, និងផ្លូវសតិ។

6. ខែថ្ងៃឆ្នាំកំណើតរបស់ខ្ញុំគឺ ៖ ____________

7. ខ្ញុំត្រូវជា ____________________ របស់អនីតិជនរូបនេះ។
(សរសេរទំនាក់ទំនងរបស់អ្នកទៅនឹងក្មេង, ឧ.ហ. ជីតា ឬជីដូន, ម្តាយមីង/ឪពុកមារ)

ខ្ញុំសូមប្រកាសនៅក្រោមទោសបញ្ញត្តិនៃការស្បថបំពាន នៅក្រោមច្បាប់នៃរដ្ឋវ៉ាស៊ិនតោនថា ពត៌មាននៅខាងលើនេះគឺពិត និងត្រឹមត្រូវ។

ខែ/ថ្ងៃ/ឆ្នាំ ៖____________ ក្រុង និងរដ្ឋ ៖ ____________________

ហត្ថលេខារបស់អ្នកផ្តល់ការមើលថែទាំ ៖ ____________________

សេចក្តីប្រកាសនេះមានសុពលភាពត្រឹមតែប្រាំមួយខែប៉ុណ្ណោះ រាប់ចាប់ពីកាលបរិច្ឆេទដែលបានចុះក្នុងនេះ។

## វិបសៃតិ៍នៃកិច្ចថែទាំដោយសាច់ញាតិរបស់រដ្ឋវ៉ាស៊ីនតោន

សំរាប់ព័ត៌មានពិស្តារស្តីអំពីធនធាន, សេវាកម្ម, ការបោះពុម្ពផ្សាយ, និងសេចក្តីត្រូវការផ្សេងៗ, សូមចូលទៅមើលវិបសៃតិ៍ ៖
**www.dshs.wa.gov/kinshipcare/**

## ការបោះពុម្ពផ្សាយដោយមិនយកថ្លៃ

សាច់ញាតិជាឪពុកម្តាយ ៖ សៀវភៅណែនាំនៃធនធានសំរាប់សាច់ញាតិដែលចិញ្ចឹមបីបាច់ក្មេងនៅក្នុងរដ្ឋវ៉ាស៊ិនតោន (DSHS 22-996x) គឺជាការណែនាំនៃធនធានដែលមានតំលៃសំរាប់អ្នកចិញ្ចឹមបីបាច់ដែលជាសាច់ញាតិទាំងអស់។ កូនសៀវភៅជួយដល់គ្រួសារក្នុងរដ្ឋវ៉ាស៊ិនតោនឲ្យរកសេវា, ការឧបត្ថម្ភ និងពត៌មានដែលគេត្រូវការ នៅពេលដែលគេចិញ្ចឹមបីបាច់ក្មេងដែលជាសាច់ញាតិ។

ដើម្បីបញ្ជាសុំកូនសៀវភៅណាមួយ, សូមចូលទៅមើលវិបសៃតិ៍ **www.prt.wa.gov** និងចុចត្រង់ "General Store" ឬក៏ទូរស័ព្ទទៅក្រសួងរោងពុម្ពតាមលេខ 360-570-3062 ។

Aging and Disability Services Administration
អភិបាលកិច្ចគ្រប់គ្រងសេវាបម្រើជនចាស់ជរា និងពិការភាព
Washington State Department of Social & Health Services
DSHS 22-1119x CA (Rev. 9/08)

# ការព្រមព្រៀងសំរាប់មើលថែទាំសុខភាព

សំរាប់

## ក្មេងនៅក្នុងការថែទាំរបស់អ្នក



ការណែនាំអ្នកមើលថែទាំដោយភាពជាសាច់ញាតិ

Washington State
Department of Social & Health Services

## ក្នុងនាមជាអ្នកផ្តល់ការមើលថែទាំដោយភាពជាសាច់ញាតិ តើខ្ញុំអាចព្រមព្រៀងចំពោះការមើលថែទាំសុខភាពសំរាប់ក្មេងនៅក្នុងការថែទាំរបស់ខ្ញុំឬទេ?

**បាទ/ចា៎ះ។** ច្បាប់ពីររបស់រដ្ឋអនុញ្ញាតឲ្យអ្នកបីបាច់ក្មេង ដែលជាប់ជាសាច់ញាតិ អាចផ្តល់សេចក្តីអនុញ្ញាតជូនអ្នកផ្តល់ការថែទាំសុខភាបសំរាប់ក្មេងបាននៅពេលណាឪពុកម្តាយពុំមានវត្តមាន។ នេះគឺជាការពិតឥតបំផ្លើស បើទោះជាអ្នកបីបាច់ក្មេងរូបនោះគ្មានសិទ្ធិអាណាព្យាបាលស្របច្បាប់ក៏ដោយ។

ក្នុងនាមជាអ្នកបីបាច់ក្មេងដែលជាប់ជាសាច់ញាតិ, អ្នកអាចផ្តល់សេចក្តីអនុញ្ញាតជូនអ្នកផ្តល់ការថែទាំសុខភាពសំរាប់ក្មេងជាអនីតិជនណាម្នាក់បាន ប្រសិនបើរូបអ្នកជានីតិជន ហើយ ៖

- មានការអនុញ្ញាតិដោយមានចុះហត្ថលេខាពីឪពុកឬម្តាយក្មេងដើម្បីធ្វើការសំរេចចិត្តការមើលថែទាំសុខភាពសំរាប់ក្មេង;
- ជាសាច់ញាតិដែលជាអ្នកទទួលខុសត្រូវសំរាប់ការមើលថែទាំសុខភាពសំរាប់ក្មេង; ឬ
- ជាអ្នកផ្តល់ការមើលថែទាំជាសាច់ញាតិ ដែលបានចុះហត្ថលេខា និងចុះថ្ងៃខែឆ្នាំនៃការប្រកាស (RCW 7.70.065)។

## តើមានការថែទាំសុខភាពប្រភេទណាខ្លះត្រូវបានរួមបញ្ចូល?

ការថែទាំសុខភាពអាចមានរួមបញ្ចូលនូវសុខភាពវេជ្ជសាស្ត្រ, ធ្មេញ, ឬផ្លូវសតិ។

## ចុះបើខ្ញុំជាអ្នកបីបាច់ក្មេងត្រូវជាប់ជាសាច់ញាតិដែលបានមានការពាក់ព័ន្ធជាមួយអភិបាលកិច្ចរបស់កុមារវិញ?

សាច់ញាតិក៏នៅតែត្រូវការមានដីកាតុលាការដែរ ដើម្បីអាចផ្តល់សេចក្តីអនុញ្ញាត ឲ្យគេធ្វើការវះកាត់ក្មេងណាម្នាក់ ដែលបានដាក់ឲ្យអ្នកជួយចិញ្ចឹមដោយនាយកដ្ឋានសេវាកុមារ និងគ្រួសារ (Division of Children and Family Services) ទៅបាននោះ។

* **SHB 1281 (2005)**
ការផ្តោតលើសេចក្តីអនុញ្ញាតជូនអ្នកថែទាំសុខភាពសំរាប់ក្មេងណាម្នាក់ដោយសាច់ញាតិជានីតិជនមានសមត្ថកិច្ច។

**SHB 3139 (2006)**
ការបន្ថែមសេវាថែទាំសុខភាពផ្លូវសតិ។

## អ្វីទៅហៅថាការប្រកាស?

ការប្រកាសគឺជាឯកសារដែលបានសរសេរចុះថ្ងៃខែឆ្នាំ និងហត្ថលេខាដែលថែងពីពត៌មាននោះថាជាការពិត។ ក្នុងនាមជាមនុស្សធំអ្នកផ្តល់ការមើលថែទាំដោយភាពជាសាច់ញាតិ, អ្នកអាចចុះហត្ថលេខាការប្រកាសដែលនិយាយថា អ្នកគឺជាអ្នកទទួលខុសត្រូវជាប់សាច់ញាតិសំរាប់មើលថែទាំសុខភាពរបស់អនីតិជន។

ទោះបីជាការប្រកាសដោយមានការចុះហត្ថលេខាមិនមែនជាការតំរូវនៅក្រោមច្បាប់ក៏ដោយ, អ្នកផ្តល់ការមើលថែទាំសុខភាពអាចតំរូវឲ្យមានការចុះហត្ថលេខានេះ។ គំរូការប្រកាសនេះអាចរកឃើញនៅក្នុងកូនសៀវភៅនេះ ឬអាចផ្ទុកក្នុងកុំព្យូទ័រពីអ៊ិនធើណែតនៅ ៖ www.washingtonlawhelp.org. អ្នកអាចប្រើក្រដាសគំរូនេះ ឬសរសេរការប្រកាសដោយខ្លួនអ្នកផ្ទាល់។

ចូរចាំទុកថា ការប្រកាសគឺមានលក្ខខ័ណ្ឌស្ថិតក្រោមទោសបញ្ញត្តិនៃការស្បថបំពានក្រោមច្បាប់នៃរដ្ឋវ៉ាស៊ិនតោន៉។ ការចុះហត្ថលេខាលើការប្រកាសនេះ ដែលអ្នកដឹងថាជាការក្លែងក្លាយគឺជាប់ទឧក្រិដកំរិត B។

## តើរយ:ពេលយូរប៉ុន្មានដែលការប្រកាសនេះនៅប្រើបាន ហើយខ្ញុំគួរធ្វើដូចម្តេចបើសិនជាផុតកំណត់ពេល ?

ការប្រកាសគឺប្រើបានសំរាប់រយ:ពេលប្រាំមួយខែ ចាប់តាំងពីថ្ងៃដែលបានចុះហត្ថលេខា។ ក្រោយរយ:ពេលប្រាំមួយខែ, ការប្រកាសផុតកំណត់។ អ្នកត្រូវតែបំពេញ ហើយចុះហត្ថលេខាលើការប្រកាសផ្សេងមួយទៀត។

## តើការចុះហត្ថលេខាលើការប្រកាសមានន័យថា ខ្ញុំមានសិទ្ធិថែរក្សាក្មេងស្របច្បាប់ឬទេ ?

**ទេ។** ការចុះហត្ថលេខាលើការប្រកាសគឺគ្រាន់តែអនុញ្ញាតឲ្យអ្នកព្រមព្រៀងមើលថែទាំក្មេងប៉ុណ្ណោះ។ ការប្រកាសគ្មានប្រសិទ្ធិភាពអ្វីដល់ការចិញ្ចឹមរក្សាក្មេងស្របច្បាប់ ឬមានសិទ្ធិស្របច្បាប់ជាមាតាបិតាទេ។

## តើខ្ញុំត្រូវធ្វើដូចម្តេច បើសិនជាអ្នកផ្តល់ការថែទាំសុខភាពស្នើសុំឲ្យផ្តល់ភស្តុតាងបន្ថែមទៀត? តើខ្ញុំអាចជាសាច់ញាតិមានភារៈទទួលខុសត្រូវក្នុងការមើលថែទាំសុខភាពក្មេងឬទេ?

នៅក្រោមសុភលភាពនៃច្បាប់បច្ចុប្បន្ន, អ្នកផ្តល់កិច្ចថែទាំសុខភាពមានសិទ្ធិសុំមើលភស្តុតាងបញ្ជាក់ថាតើអ្នកពិតជាជនមានភារៈទទួលខុសត្រូវលើសុខភាពរបស់ក្មេងមែនឬទេ។ អ្នកផ្តល់កិច្ចបថែទាំសុខភាពអាចរួមមាននូវជនឬអង ការណាមួយដូចតទៅគឺ៖ អ្នកផ្តល់កិច្ចថែទាំសុខភាពវេជ្ជសាស្ត្រ, ខុសភាព
ធ្មេញ, ឬសុខភាពផ្លូវសតិ។ បើការនេះកើតឡើង, នោះវត្ថុតាងនានាខាងក្រោមនេះអាចមានសារប្រយោជន៍ ៖

(1) សំបុត្របណ្តាំដែលមានប្រាប់អំពីទំនាក់ទំនងរបស់អ្នកទៅនឹងក្មេង។
(2) លិខិតមកពីអ្នកធ្វើការផ្នែកសង មកិច្ច, បុគ លិកសាលារៀន, មេធាវី, អ្នកដឹកនាំសាសនា, ឬអ្នកមានវិជ្ជាជីវ:មានវិញ្ញាបនប័ត្រផ្នែកពេទ្យ, ផ្នែកសុខភាពផ្លូវសតិ, ឬផ្នែកចរិយាដែលបង្ហាញពីទំនាក់ទំនងរបស់អ្នកទៅនឹងក្មេង។
(3) ឯកសារមកពីសាលារៀន, មន្ទីរពេទ្យ, មន្ទីរព្យាបាល, ឬទីភ្នាក់ងារសុខភាពសាធារណ:, ឬទីភ្នាក់ងារសង មកិច្ច ដែលបង្ហាញពីទំនាក់ទំនងរបស់អ្នកទៅនឹងក្មេង។
(4) ភស្តុតាងដែលអ្នកទទួលពីជំនួយសាធារណ: ដូចជា TANF, SSI, ប័ណ្ណផ្នែកពេទ្យ, ខិតប័ណ្ណម្ហូបអាហារ, ឬការទទួលអាហារពីសាលារៀនដោយមិនយកថ្លៃ/បន្ថយថ្លៃក្នុងនាមរបស់ក្មេង។
(5) ឯកសារពីក្រសួងសង មកិច្ច និងសុខាភិបាល ដែលបង្ហាញថាអ្នកគឺជាជនបងេ ។លសំរាប់ឲ្យគេធ្វើការប្រស្រ័យទាក់ទងសំរាប់ក្មេង។
(6) ភស្តុតាងដែលក្មេងរស់នៅក្នុងអាគាររបស់អ្នក ឬផ្ទះផ្សេងទៀតដែលជាប់ទាក់ទងនឹងអ្នក។
(7) ការធានារ៉ាប់រងសំរាប់អ្នក ឬក្មេងដែលថ្លែងថាក្មេងជាសាច់ញាតិរបស់អ្នក។
(8) ក្រដាសប្រាក់ពន្ធលើប្រាក់ចំណូលសងមកវិញ ដែលក្នុងនោះក្មេងមានរាយឈ្មោះ។
(9) ឯកសារដទៃផ្សេងទៀតដែលបង្ហាញពីទំនាក់ទំនងរបស់អ្នកជាមួយក្មេង ហើយបង្ហាញថា អ្នកគឺជាអ្នកផ្តល់ការមើលថែទាំសំរាប់ក្មេងនោះ។

## តើខ្ញុំអាចទទួលជំនួយពីកន្លែងណា ?

គឺមានអង ការជាច្រើនដែលផ្តល់ពត៌មានផ្នែកច្បាប់ដែលមិនយកប្រាក់ និងការបញ្ជូនតាមទូរស័ព្ទ និង/ឬតាមពត៌មានក្នុងអ៊ិនធើណែត។

### សំរាប់ព័ត៌មានពិស្តារបន្ថែម

**The Coordinated Legal Education, Advice and Referral (CLEAR)**
**(ការអប់រំផ្នែកច្បាប់ដែលបានសម្របសម្រួល, គាំទ្រ, និងផ្តល់ការបញ្ជូន)**

បើសិនជាអ្នកមានអាយុនៅក្រោម 60 ឆ្នាំ ហើយមានប្រាក់ចំណូលតិច, ចូរទូរស័ព្ទលេខ **1-888-201-1014***។

បើសិនជាអ្នកមានអាយុច្រើនជាង 60 ឆ្នាំ នៅក្នុងកំរិតប្រាក់ចំណូលណាមួយ ចូរទូរស័ព្ទ CLEAR ដោយមិនយកថ្លៃ តាមលេខ **1-888-387-7111** ។

អ្នកអាចផ្ទុកក្នុងកុំព្យូទ័រនៃគំរូការប្រកាសមកពីវ៉ិបសៃតិ៍ **www.washingtonlawhelp.org**

**មណ្ឌល The Northwest Women's Law Center**

ចូរទូរស័ព្ទលេខ **206-621-7692** (សំរាប់ទាំងពីរភេទគឺស្ត្រី និងបុរស)

មើលវ៉ឹបសៃតិ៍ នៅ **www.nwwlc.org/**

* មិនអាចមាននៅឃីងខោនធី។ គេហជននៅឃីងខោនធី អាចទូរស័ព្ទទៅលេខ 206-464-1519 សំរាប់ពត៌មាននឹងការបញ្ជូន។